សណ្ឋាគារសូហ្វីតែល ភូគីត្រា ភ្នំពេញ ថ្ងៃចន្ទ ១២ រោច ខែមិគសិរ ឆ្នាំរកា ព.ស. ២៥៦១
ត្រូវនឹងថ្ងៃទី១៥ ខែធ្នូ គ.ស. ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

# ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារក្នុងសិក្ខាសាលាស្តីពី "ប្រព័ន្ធពន្ធដារកម្ពុជា" ជូនសភាពាណិជ្ជកម្មចិននៅកម្ពុជា




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាវេលាម៉ោង ៩:០០នាទីព្រឹក ថ្ងៃសុក្រ ១២រោច ខែមិគសិរ ឆ្នាំរកា ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី១៥ ខែធ្នូ គ.ស. ២០១៧ មានការរៀបចំនូវកម្មវិធីសិក្ខាសាលា របស់សភាពាណិជ្ជកម្មចិននៅកម្ពុជាស្តីពី "ប្រព័ន្ធពន្ធដារកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ និង លោក **ភាវ ហ័រ** ប្រធានសភាពាណិជ្ជកម្មចិននៅកម្ពុជា ដោយមានការចូលរួមជាកិត្តិយសពីសំណាក់ ឯកឧត្តម **លី អាន** ទីប្រឹក្សាសេដ្ឋកិច្ចនិងពាណិជ្ជកម្ម របស់ស្ថានទូតសាធារណៈរដ្ឋប្រជាមានិតចិនប្រចាំនៅកម្ពុជា លោកប្រធាននាយកដ្ឋាន និងមន្ត្រីជំនាញមួយចំនួននៃអគ្គនាយកដ្ឋានពន្ធដារ និងវត្តមានរបស់លោកឧកញ៉ា លោកជំទាវ លោក លោកស្រី តំណាង វិនិយោគិនរោងចក្រ សហគ្រាសនានា ដែលភាគច្រើនជាអ្នកវិនិយោគិនជនជាតិចិន។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម គង់ វិបុល បានបញ្ជាក់ថាវេទិកាពន្ធដារ និងសភាពាណិជ្ជកម្មចិន នេះគឺជាការរៀបចំលើកទីមួយដែលមានសារៈសំខាន់យ៉ាងខ្លាំង ស្របពេលដែលការវិនិយោគផ្ទាល់ពីប្រទេសចិន គឺចូលរួមយ៉ាងសំខាន់ ចំពោះកំណើន



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

សេដ្ឋកិច្ចកម្ពុជា ព្រោះបើគិតចាប់ពីឆ្នាំ១៩៩៤ មកទល់នឹងបច្ចុប្បន្ន ទំហំនៃការវិនិយោគផ្ទាល់របស់ប្រទេសចិន គឺឈរនៅលំដាប់លើគេ ក្នុងចំណោមការវិនិយោគផ្ទាល់ពីបរទេស ដែលបានវិនិយោគលើវិស័យសំខាន់ៗមានជាអាទិ ទី១. វិស័យកសិកម្ម និងកសិឧស្សាហកម្ម, វិស័យឧស្សាហកម្ម និងកាម្មន្តសាល, វិស័យទេសចរណ៍, និង វិស័យសេវាកម្មនិងហេដ្ឋារចនាសម្ព័ន្ធ។

ក្នុងឱកាសនោះ អគ្គនាយកដ្ឋានពន្ធដារ ចែករំលែកនូវវឌ្ឍនភាពថ្មីៗបំផុត ពាក់ព័ន្ធនឹងផ្នែកគោលនយោបាយ ច្បាប់ និង បទប្បញ្ញត្តិស្ដីសារពើពន្ធនិង ជាពិសេសការលើកទឹកចិត្តផ្នែកពន្ធដារផងដែរ។ គួរបញ្ជាក់ផងដែរថា គោលនយោបាយក្នុងការលើកទឹកចិត្តផ្នែកវិនិយោគ គឺមានភាពប្រទាក់ក្រឡាគ្នាយ៉ាងសំខាន់ ជាមួយនឹងគោលនយោបាយនានា ផ្នែកសារពើពន្ធ ដើម្បីជំរុញនិងពង្រឹងការគ្រប់គ្រងប្រមូលពន្ធឱ្យបានសម្រេចតាមផែនការច្បាប់កំណត់។ រាជរដ្ឋាភិបាលកម្ពុជាក្នុងអាណត្តិទី ៥ បាននិងកំពុង អនុវត្តយ៉ាងហ្មត់ចត់នូវយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ ២០១៤-២០១៨ ក្នុងនោះគឺ ទី១. មិនមានការបង្កើនអត្រាពន្ធឬបង្កើតពន្ធថ្មី ទី២. មានតែពង្រឹងច្បាប់ និងបទប្បញ្ញត្តិស្ដីពីពន្ធដារមានស្រាប់ ទី៣. ពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធ ឱ្យអស់សក្ដានុពលដែលមានស្រាប់ និង ទី៤. ធានាឱ្យបាននូវភាពងាយស្រួល សមធម៌ និងភាពត្រឹមត្រូវក្នុងការបង់ពន្ធ។ ជាផែនការយុទ្ធសាស្ត្របន្ត អគ្គ-នាយកដ្ឋានពន្ធដារ បានត្រៀមអនុវត្តបន្តនូវយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ដំណាក់កាលទី២ ដើម្បីបន្តនូវភាពជោគជ័យនៃកំណែទម្រង់របស់រាជរដ្ឋាភិបាល លើវិស័យពន្ធដារជាបន្តទៀត ក្នុងន័យធានានូវអភិបាលកិច្ចល្អ បរិយាកាសធុរកិច្ចដ៏ប្រសើរ និងការប្រកួតប្រជែងដោយស្មើភាពគ្នា ចំពោះគ្រប់ធុរជន តាមរយៈការប្រមូលចំណូលពន្ធ ប្រកបដោយតម្លាភាព ប្រសិទ្ធភាព ស័ក្ដិសិទ្ធិភាព និងសមធម៌។

ឆ្លៀតក្នុងឱកាសនោះដែរ ឯកឧត្ដមប្រតិភូរាជរដ្ឋាភិបាល បានជំរុញឱ្យរោងចក្រសហគ្រាសនានា របស់វិនិយោគិនចិនទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជាមកចុះបញ្ជីពន្ធដារ និងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសឱ្យបានគ្រប់ៗគ្នា ក្នុងគោលដៅបង្កលទ្ធភាពជូនអគ្គនាយកដ្ឋានពន្ធដារ ក្នុងការផ្ដល់សេវាជូនអ្នកជាប់ពន្ធឱ្យបានពេញលេញរួមមាន ការទទួលបានព័ត៌មានថ្មីៗតាមទូរស័ព្ទដៃ និង E-mail អំពីការរំលឹកចំនួនទឹកប្រាក់ពន្ធបានបង់, និងការបង់ពន្ធតាមប្រព័ន្ធ E-Payment ជាដើម។ ស្របពេលដែលប្រទេសកម្ពុជា និងប្រទេសចិនបានចុះកិច្ចព្រមព្រៀងនៃការចៀសវាងការយកពន្ធត្រួតគ្នា (DTA) កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ហើយដែលទើបទទួលបាននូវសត្យាប័ន ពីអង្គនីតិបញ្ញត្តិនាពេលថ្មីៗនេះ ដូចនេះ កិច្ចព្រមព្រៀងនេះ នឹងឈានទៅអនុវត្តនាពេលអនាគតដ៏ខ្លី ដើម្បីជាប្រយោជន៍ដល់ទាំងវិនិយោគិន រោងចក្រ សហគ្រាសរបស់ជនជាតិចិននៅប្រទេសកម្ពុជា និងជនជាតិកម្ពុជានៅប្រទេសចិន តាមរយៈទទួលបានអត្ថប្រយោជន៍ជាច្រើន ពីការអនុវត្តកិច្ចព្រមព្រៀងនេះ។ ទន្ទឹមនឹងគ្នានេះ ឯកឧត្ដមប្រតិភូរាជរដ្ឋាភិបាល សូមកើនរំលឹកដល់សហគ្រាសទាំងអស់ចូលរួម និងគាំទ្រការពង្រឹងវប្បធម៌នៃ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ការបង់ពន្ធឲ្យបានគ្រប់ៗគ្នា ដើម្បីចៀសវាងនូវទោសទណ្ឌនានា ដែលកើតឡើងពីការគេចវេះបន្ធំពន្ធ។

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលក៏បានបញ្ជាក់ថា ទន្ទឹមនឹងការខិតខំធ្វើកំណែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារ រោងចក្រ សហគ្រាស អ្នកជាប់ពន្ធនានាក៏ត្រូវតែកែទម្រង់ និងកែលម្អខ្លួនផងដែរ តាមរយៈគាំទ្រការពង្រឹងវប្បធម៌នៃការបង់ពន្ធ និងអនុលោមភាពសារពើពន្ធ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិទាំងអស់គ្នា។

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានថ្លែងអំណរគុណចំពោះតំណាងស្ថានទូតសាធារណៈរដ្ឋប្រជាមានិតចិនប្រចាំនៅកម្ពុជា និងសភាពាណិជ្ជកម្មចិននៅកម្ពុជា ក្នុងការសហការជាមួយអគ្គនាយកដ្ឋានពន្ធដារ រៀបចំសិក្ខាសាលានាថ្ងៃនេះ និងសូមជូនពរ ឯកឧត្តម-លោកជំទាវ លោកឧកញ៉ា លោក-លោកស្រី សូមសមប្រកបនឹងពុទ្ធិពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ